**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលមាត្រា ៤, មាត្រា ៦, មាត្រា ៨, មាត្រា ១០ និងមាត្រា ១១ នៃអនុក្រឹត្យ លេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រាមួយ.-**

មាត្រា ៤, មាត្រា ៦, មាត្រា ៨, មាត្រា ១០ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា ៤.- ថ្មី**

មូលនិធិបរិស្ថាន និងសង្គម ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | អនុប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ១ រូប | សមាជិក |
| - តំណាងក្រសួងរ៉ែ និងថាមពល | ១ រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | សមាជិក |
| - តំណាងក្រសួងធនធានទឹក និងឧតុនិយម | ១ រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ១ រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១ រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១ រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន | ១ រូប | សមាជិក |
| - ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម | ១ រូប | សមាជិក ។ |

រាជរដ្ឋាភិបាលអាចចាត់តាំងឥស្សរជនជាន់ខ្ពស់មួយរូប ធ្វើជាប្រធានកិត្តិយសនៃគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម តាមសំណើរបស់ប្រធានគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៦.. ថ្មី**

គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម មានលេខាធិការដ្ឋានមួយស្ថិតនៅក្នុងក្រសួងបរិស្ថាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

**មាត្រា ៨.. ថ្មី**

មូលនិធិបរិស្ថាន និងសង្គម មានប្រភពចំណូលមកពី៖

- ទុនដំបូងរបស់រាជរដ្ឋាភិបាល
- ភាគទានបានមកពីអាករពិសេសពាក់ព័ន្ធនឹងវិស័យបរិស្ថានតាមការកំណត់របស់រាជរដ្ឋាភិបាល
- ភាគទានបានមកពីកម្រៃសេវាវិស័យអាកាសចរស៊ីវិលតាមការកំណត់របស់រាជរដ្ឋាភិបាល
- បុព្វលាភបានមកពីម្ចាស់គម្រោងអភិវឌ្ឍន៍ឯកជន និងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬ កិច្ចសន្យាការពារបរិស្ថាន
- ប្រាក់ចំណូលបានមកពីកិច្ចគាំពារបរិស្ថាន សេវាប្រព័ន្ធអេកូឡូស៊ី និងអភិរក្សជីវៈចម្រុះ
- ភាគទានបានមកពីមូលនិធិទាយជ្ជទានបរិស្ថាន
- ភាគទានបានមកពីមូលនិធិតំបន់ការពារធម្មជាតិ
- ភាគទានបានមកពីកម្រៃសេវាលក់សំបុត្រចូលទស្សនាតំបន់ការពារធម្មជាតិ
- កម្រៃសេវាកម្មជួលទីតាំងដំឡើងបង្គោលអង់តែន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន
- ភាគទានបានមកពីកម្រៃសេវាកម្មជួលទីតាំងដំឡើងបណ្តាញអគ្គិសនី និងបណ្តាញខ្សែកាបអុបទិក ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន
- ភាគទានបានមកពីកម្រៃជួលទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិទំហំក្រោម ១០ ហិកតា ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន
- ភាគទានបានមកពីការលក់ឥណទានកាបូន
- អំណោយ ឬជំនួយថវិកា សម្ភារ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- ភាគទានបានមកពីកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ប្រភពផ្សេងៗទៀត ។

**មាត្រា ១០.. ថ្មី**

មូលនិធិបរិស្ថាន និងសង្គម ត្រូវប្រើប្រាស់ក្នុងសកម្មភាពដូចខាងក្រោម៖

- កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី និងការរស់នៅដោយចីរភាព
- ការស្តារបរិស្ថាន និងការកែលម្អធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ
- ការសិក្សាស្រាវជ្រាវលើបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
- ការចូលរួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលរស់នៅក្នុង និងក្បែរតំបន់គម្រោងវិនិយោគអភិវឌ្ឍន៍ ឬតំបន់ផ្សេងទៀត
- ការចូលរួមគាំទ្រដល់ការរៀបចំបង្កើត និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន



ឋ

- ការចូលរួមគាំទ្រគម្រោងអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន រួមទាំងការផ្ដល់ឥណទានខ្នាតតូចជាលក្ខណៈទុនបង្វិល
- ការអប់រំ និងការផ្សព្វផ្សាយអំពីបរិស្ថាន ធនធានធម្មជាតិនិងវប្បធម៌ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
- ការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាន និងធនធានធម្មជាតិ
- សកម្មភាពផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា ១១.- ថ្មី**

នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការគ្រប់គ្រងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គមប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ អង្គារ ៥ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ